បកប្រែក្រៅផ្លូវការ

# សេចក្តីថ្លែងការណ៍រួមរបស់នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រថៃ ស្តីពីលទ្ធផលនៃជំនួបរវាងនាយករដ្ឋមន្ត្រីទាំងពីរនៅទីក្រុងកូឡាឡាំពួរ ប្រទេសម៉ាឡេស៊ី

---------------------------

យើង នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រថៃ និងដោយមានប្រធានាធិបតីសហរដ្ឋអាមេរិក និងនាយករដ្ឋមន្ត្រីម៉ាឡេស៊ី ធ្វើជាសាក្សី បន្ទាប់ពីបានជួបប្រជុំគ្នានៅទីក្រុងគូឡាឡាំពួរ ប្រទេសម៉ាឡេស៊ី នៅថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២៥ សូមប្រកាសដូចខាងក្រោម៖

១. យើងសូមបញ្ជាក់ជាថ្មីនូវការប្តេជ្ញាចិត្តដ៏រឹងមាំចំពោះសន្តិភាព និងសន្តិសុខរវាងប្រទេសយើងទាំងពីរ ដូចដែលបានប្រកាសនៅទីក្រុងពូត្រាចាយ៉ា ប្រទេសម៉ាឡេស៊ី ពីថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២៥ - ហើយសូមគូសបញ្ជាក់ជាថ្មីនូវការប្តេជ្ញាចិត្តយ៉ាងមុតមាំរបស់យើងចំពោះការចៀសវាងការគំរាមកំហែងប្រើប្រាស់ ឬប្រើប្រាស់កម្លាំង ការដោះស្រាយជម្លោះដោយសន្តិវិធី និងការគោរពព្រំដែនអន្តរជាតិ និងច្បាប់អន្តរជាតិ ដើម្បីលើកកម្ពស់សន្តិភាព សន្តិសុខ ស្ថិរភាព និងវិបុលភាពនៅក្នុងតំបន់ ដោយឈរលើមូលដ្ឋាននៃការគោរពឯករាជ្យ អធិបតេយ្យ សមភាព បូរណភាពទឹកដី និងអត្តសញ្ញាណជាតិទៅវិញទៅមករវាងប្រទេសយើងទាំងពីរ។

២. យើងសូមបញ្ជាក់ជាថ្មីនូវការប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការគោរព និងអនុវត្តកិច្ចព្រមព្រៀងដែលភាគីទាំងពីរសម្រេចបាននៅក្នុងកិច្ចប្រជុំគណៈកម្មាធិការព្រំដែនទូទៅ។

៣. យើងបានចុះហត្ថលេខាលើលក្ខខណ្ឌយោងស្តីពីការបង្កើតក្រុមអ្នកសង្កេតការណ៍អាស៊ាន (AOT) ដែលមានសមាសភាពជាបុគ្គលិកមកពីរដ្ឋសមាជិកអាស៊ាន និងមានគោលបំណងធានាការអនុវត្តបទឈប់បាញ់ឲ្យបានពេញលេញ និងមានប្រសិទ្ធភាព។ យើងសូមអំពាវនាវដល់រដ្ឋសមាជិកអាស៊ានឱ្យផ្តល់ការគាំទ្រសមស្រប ដើម្បីធានាថា AOT អាចសម្រេចគោលបំណងរបស់ខ្លួនបានដោយជោគជ័យ។

៤. បន្ថែមលើនេះ យើងបានប្តេជ្ញាចិត្តក្នុងការបន្ថយភាពតានតឹង ស្តារទំនុកចិត្ត និងទំនាក់ទំនងដែលផ្តល់ផលប្រយោជន៍ទៅវិញទៅមករវាងព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រថៃ។ ដើម្បីសម្រេចបាន និងពង្រឹងគោលបំណងទាំងនេះ យើងបានឯកភាពចំពោះជំហានដូចខាងក្រោម ដើម្បីធានាការអនុវត្តបទឈប់បាញ់ឲ្យបានពេញលេញ និងមានប្រសិទ្ធភាព និងស្តារឡើងវិញនូវសន្តិភាព សន្តិសុខ និងស្ថិរភាពនៅតំបន់ព្រំដែន៖

- អនុវត្តការបន្ធូរបន្ថយភាពតានតឹងផ្នែកយោធាក្រោមការសង្កេត និងការផ្ទៀងផ្ទាត់របស់ AOT ដោយរួមបញ្ចូលទាំងការដកអាវុធ និងឧបករណ៍បំផ្លិចបំផ្លាញធុនធ្ងន់ ចេញពីព្រំដែន និងបញ្ជូនត្រឡប់ទៅទីតាំងមូលដ្ឋានយោធាដូចដើមវិញ។ ក្នុងបរិបទនេះ ភាគីទាំងពីរនឹងចាត់តាំងក្រុមការងាររៀងៗខ្លួនដើម្បីពិភាក្សាគ្នាឈានទៅរៀបចំឲ្យបានសម្រេចនូវផែនការសកម្មភាពជាក់ស្តែង និងជាជំហានៗ ដែលនឹងត្រូវអនុវត្តក្រោមការសង្កេតរបស់ IOT (ក្រុមសង្កេតការណ៍អាស៊ានបណ្តោះអាសន្ន) ហើយបន្ទាប់មក AOT នៅពេលដែលយន្តការនេះត្រូវបានបង្កើតឡើង បន្ទាប់ពីការចុះហត្ថលេខាលើលក្ខខណ្ឌយោង។

- ជៀសវាងការចែកចាយ ឬផ្សព្វផ្សាយព័ត៌មានមិនពិត ការចោទប្រកាន់ ការអះអាងដោយគ្មានភស្តុតាង និងវោហាសាស្ត្រដែលបង្កគ្រោះថ្នាក់ ទាំងតាមបណ្តាញផ្លូវការរបស់រដ្ឋាភិបាល ឬវេទិកាក្រៅផ្លូវការ ដើម្បីបន្ថយភាពតានតឹង កាត់បន្ថយសតិអារម្មណ៍អវិជ្ជមានរបស់សាធារណជន និងលើកកម្ពស់បរិយាកាសអំណោយផលដល់ការសន្ទនាដោយសន្តិវិធី។
- ឯកភាពលើការអនុវត្តដោយគ្មានបង្អែបង្អង់ និងយ៉ាងពេញលេញនូវវិធានការកសាងទំនុកចិត្ត ដើម្បីស្តារ និងរក្សាទំនុកចិត្ត ការជឿទុកចិត្តគ្នាទៅវិញទៅមក និងសន្តិភាពតាមបណ្តោយព្រំដែន ហើយដោះស្រាយទំនាស់ដោយសន្តិវិធី ក្នុងស្មារតីជាអ្នកជិតខាងល្អ មិត្តភាព និងសាមគ្គីភាព ព្រមទាំងធ្វើការឆ្ពោះទៅរកការស្តារទំនាក់ទំនងការទូតរវាងប្រទេសទាំងពីរឡើងវិញ។
- សម្របសម្រួល និងអនុវត្តការបោសសំអាតមីនមនុស្សធម៌នៅតំបន់ព្រំដែន ដូចបានព្រមព្រៀងគ្នាដោយគណៈកម្មាធិការព្រំដែនទូទៅ ដោយមិនប៉ះពាល់ដល់ការវាស់វែង និងខណ្ឌសីមាព្រំដែនគោករវាងប្រទេសទាំងពីរ សំដៅការពារជីវិតជនស៊ីវិល និងរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គម។
- បញ្ជាក់ឡើងវិញនូវការប្តេជ្ញាចិត្តរបស់យើង ក្នុងការដោះស្រាយបញ្ហាទំនាស់ព្រំដែន និងខណ្ឌសីមាព្រំដែនតាមសន្តិវិធី និងច្បាប់អន្តរជាតិ ដោយចៀសវាងការគំរាមកំហែងប្រើប្រាស់ ឬការប្រើប្រាស់កម្លាំង ឬទង្វើញុះញង់ ហើយទទួលស្គាល់ថា គណៈកម្មាធិការព្រំដែនថ្នាក់ភូមិភាគ គណៈកម្មាធិការព្រំដែនទូទៅ និងគណៈកម្មការចម្រុះខណ្ឌសីមាព្រំដែន គឺជាយន្តការទ្វេភាគីដែលមានអាណត្តិការងាររៀងៗខ្លួន សម្រាប់ធ្វើការដោះស្រាយបញ្ហាពាក់ព័ន្ធនឹងព្រំដែន តាមសន្តិវិធី និងដោយមានការសម្របសម្រួលជាមួយអភិបាលខេត្ត/ស្រុកនៅមូលដ្ឋាន សំដៅគ្រប់គ្រងស្ថានការណ៍នៅនឹងកន្លែង ក្នុងនោះរួមមាន ការដោះស្រាយបញ្ហានៃការចោទប្រកាន់ពីការទន្ទ្រានដីពីសំណាក់ភាគីណាមួយ ដោយអនុលោមទៅតាមលទ្ធផលនៃកិច្ចពិភាក្សារបស់គណៈកម្មការចម្រុះខណ្ឌសីមាព្រំដែន និងការបញ្ឈប់នូវរាល់សកម្មភាពដែលពង្រីកវិសាលភាពជម្លោះ និងបង្កើនភាពតានតឹង។

៥. នៅពេលអនុវត្តវិធានការដែលបានរៀបរាប់ខាងលើប្រកបដោយប្រសិទ្ធភាព ភាគីទាំងពីរនឹងទទួលស្គាល់ថាអរិភាពសកម្មត្រូវបានបញ្ចប់។ លើសពីនេះ ដើម្បីបង្ហាញពីបំណងប្រាថ្នារបស់ប្រទេសថៃក្នុងការលើកកម្ពស់ទំនុកចិត្ត និងការជឿទុកចិត្តគ្នាទៅវិញទៅមក ប្រទេសថៃនឹងដោះលែងឈ្លើយសឹកដោយគ្មានបង្អែបង្អង់។

៦. យើងយល់ព្រមបង្កើនកិច្ចសហប្រតិបត្តិការ ការចែករំលែកព័ត៌មាន និងកិច្ចខិតខំប្រឹងប្រែងផ្សព្វផ្សាយជាយុទ្ធសាស្ត្រ ព្រមទាំងពង្រឹងការគ្រប់គ្រងព្រំដែន ដើម្បីទប់ស្កាត់ និងបង្ក្រាបឧក្រិដ្ឋកម្មឆ្លងដែនដែលប៉ះពាល់ដល់ទាំងប្រជាពលរដ្ឋរបស់យើងទាំងពីរ និងសហគមន៍អន្តរជាតិជាទូទៅផងដែរ។

៧. យើងទទួលស្គាល់ពីភាពចាំបាច់ត្រូវកំណត់នូវមាគ៌ាសម្រាប់អនាគតដ៏ភ្លឺស្វាងមួយ ដែលមិនជាប់ជំពាក់នូវចំណងជម្លោះពីអតីតកាល។ រដ្ឋាភិបាលទាំងពីរបញ្ជាក់ជាថ្មីអំពីការប្តេជ្ញាចិត្តក្នុងការដោះស្រាយជម្លោះដោយសន្តិវិធី ដោយគោរពយ៉ាងពេញលេញចំពោះច្បាប់អន្តរជាតិ ក៏ដូចជាសន្ធិសញ្ញា និងកិច្ចព្រមព្រៀងដែលមានស្រាប់។ លក្ខខណ្ឌទាំងនេះត្រូវបានបង្កើតឡើងសម្រាប់ឱ្យប្រទេសរបស់យើងមើលឆ្ពោះទៅមុខ ហើយចាប់ផ្តើមកសាងទំនាក់ទំនងជាអ្នកជិតខាងគ្នាស្របតាមខ្លឹមសារ និងស្មារតីនៃធម្មនុញ្ញអង្គការសហប្រជាជាតិ និង

គោលការណ៍ដែលមានចែងក្នុងធម្មនុញ្ញអាស៊ាន ស្តីពីការដោះស្រាយជម្លោះដោយសន្តិវិធី ដោយត្រួសត្រាយផ្លូវសម្រាប់ការចាប់ផ្តើមនូវទំព័រថ្មីនៃសន្តិភាព និងកិច្ចសហប្រតិបត្តិការរវាងប្រទេសយើងទាំងពីរ។

៨. យើងខ្ញុំសូមសម្តែងនូវទំនុកចិត្តថា កិច្ចប្រជុំនេះ ដោយមានវត្តមាន និងការគាំទ្រពីសំណាក់ប្រធានាធិបតី **ដូណាល់ ត្រាំ** នៃសហរដ្ឋអាមេរិក និង នាយករដ្ឋមន្ត្រី **អាន់វ៉ា អ៊ីប្រាហ៊ីម** នៃប្រទេសម៉ាឡេស៊ី គឺជាមូលដ្ឋានគ្រឹះដ៏រឹងមាំសម្រាប់ការគោរពគ្នាទៅវិញទៅមក និងការជំរុញសន្តិភាពនៅក្នុងតំបន់។ យើងខ្ញុំសូមកត់សម្គាល់ដោយការកោតសរសើរយ៉ាងជ្រាលជ្រៅចំពោះការរួមចំណែកយ៉ាងសំខាន់របស់ប្រធានាធិបតី **ដូណាល់ ត្រាំ** ក្នុងការជំរុញការស្តារឡើងវិញនូវទំនាក់ទំនងទ្វេភាគីប្រកបដោយផ្លែផ្កាវាងព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រថៃ។

ចុះហត្ថលេខានៅទីក្រុងកូឡាឡាំពួរ នៅថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២៥ ជាប្អូនច្បាប់ ជាភាសាអង់គ្លេស។

| | |
|---|---|
| ហ៊ុន ម៉ាណែត<br>នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា | អានុទីន ឆានវីរៈគុណ<br>នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រថៃ |
| ធ្វើជាសាក្សីដោយ៖ | ធ្វើជាសាក្សីដោយ៖ |
| ឯកឧត្តម អាន់វ៉ា អ៊ីប្រាហ៊ីម<br>នាយករដ្ឋមន្ត្រីម៉ាឡេស៊ី | **ដូណាល់ ត្រាំ**<br>ប្រធានាធិបតីនៃសហរដ្ឋអាមេរិក |